# ព្រះរាជក្រឹត្យ

នស/រកត/០៩០៩/៩៦៦

ស្តីពី

## ការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដែលសរសេរកាត់ថា ក.ក.ជ. ដើម្បីធ្វើជាសេនាធិការឱ្យរាជរដ្ឋាភិបាល លើការងារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## សមាសភាព

**មាត្រា២.-**

សមាសភាព ក.ក.ជ. មានដូចតទៅ÷

- ឥស្សរជនជាន់ខ្ពស់ មួយរូប ប្រធាន
- ឥស្សរជនមួយ ឬ ច្រើនរូប អនុប្រធាន
- អនុប្រធានទី ១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ឬ តំណាង មួយរូប សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី មួយរូប សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មួយរូប សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ មួយរូប សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មួយរូប សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ មួយរូប សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងសុខាភិបាល មួយរូប សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មួយរូប សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម មួយរូប សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងបរិស្ថាន មួយរូប សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម មួយរូប សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងផែនការ មួយរូប សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន មួយរូប សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មួយរូប សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងកិច្ចការនារី មួយរូប សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា មួយរូប សមាជិក

- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មួយរូប សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មួយរូប សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មួយរូប សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងទេសចរណ៍ មួយរូប សមាជិក
- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬ តំណាង មួយរូប សមាជិក
- ទេសាភិបាលធនាគារជាតិនៃកម្ពុជា ឬ តំណាង មួយរូប សមាជិក
- ប្រធានធនាគារអភិវឌ្ឍជនបទ ឬ តំណាង មួយរូប សមាជិក
- ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ឬ តំណាង មួយរូប សមាជិក
- ប្រធានអាជ្ញាធរទន្លេសាប ឬ តំណាង មួយរូប សមាជិក
- មេបញ្ជាការ បញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទមួយរូប សមាជិក
- អគ្គលេខាធិការក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ សមាជិកអចិន្ត្រៃយ៍

សមាសភាពជាក់ស្តែង ក.ក.ជ. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី៣

## តួនាទីនិងភារកិច្ច

**មាត្រា៣.-**

ក.ក.ជ. មានតួនាទី ជាគណៈបញ្ជាការឯកភាពមួយ ជួយរាជរដ្ឋាភិបាល ក្នុងកិច្ចសម្របសម្រួលការអភិវឌ្ឍវិស័យកសិកម្ម និងជនបទ ដោយសហការគ្នាយ៉ាងជិតស្និទ្ធជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងវិស័យឯកជនឱ្យមានប្រសិទ្ធភាព ។

**មាត្រា៤.-**

ក.ក.ជ. មានភារកិច្ចដូចខាងក្រោម ÷

- កំណត់អាទិភាព កត្តាគន្លឹះ និងកម្មវិធីនយោបាយក្នុងការអភិវឌ្ឍវិស័យកសិកម្ម និងជនបទ ឱ្យស្របតាមគោលនយោបាយនៃរាជរដ្ឋាភិបាល
- ធ្វើជាតំណាងរាជរដ្ឋាភិបាលក្នុងកិច្ចប្រជុំជាមួយអន្តរជាតិ និងដៃគូអភិវឌ្ឍនានា ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យកសិកម្ម និងជនបទ
- ទទួលបន្ទុកចាត់ចែង សម្របសម្រួល តាមដាន វាយតម្លៃ និងផ្តល់យោបល់លើការរៀបចំ ការអនុវត្តកម្មវិធី ព្រមទាំងគោលនយោបាយនៃរាជរដ្ឋាភិបាល លើការអភិវឌ្ឍវិស័យកសិកម្ម និងជនបទ
- សម្របសម្រួល ត្រួតពិនិត្យ តាមដាន និងវាយតម្លៃ រាល់ការអនុវត្តគម្រោងនានា ទាក់ទងនឹងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងវិស័យឯកជន ដើម្បីបង្កើនប្រសិទ្ធភាពការងារ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

- ចលនា និងសម្របសម្រួលឱ្យមានការចូលរួមយ៉ាងកុះករពីប្រជារាស្ត្រ សហគមន៍ជនបទ វិស័យឯកជន ដៃគូអភិវឌ្ឍ សង្គមស៊ីវិល ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កនូវភាពងាយស្រួល ព្រមទាំងសហការគ្នាល្អក្នុងការស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ សំដៅកាត់បន្ថយភាពក្រីក្រនៅកម្ពុជា
- ជំរុញ លើកទឹកចិត្ត និងបញ្ជ្រាបគោលនយោបាយយេនឌ័រ និងជនជាតិដើមភាគតិច ទៅក្នុងការអភិវឌ្ឍវិស័យកសិកម្ម និងជនបទ
- កំណត់បញ្ហាអន្តរវិស័យដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យកសិកម្ម និងជនបទ និងជំរុញការដាក់បញ្ចូលបញ្ហាទាំងនេះ ទៅក្នុងកិច្ចពិភាក្សាគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល
- ប្រជុំបូកសរុបលទ្ធផលការងាររបស់ គ.ក.ជ. និងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

## ជំពូកទី៤

## ការប្រព្រឹត្តទៅរបស់គ.ក.ជ.

**មាត្រា៥.-**

ប្រធាន គ.ក.ជ. មានតួនាទី និងភារកិច្ចដូចតទៅ ៖

- ទទួលខុសត្រូវលើការងាររបស់ គ.ក.ជ.
- ធ្វើជាអធិបតី ក្នុងអង្គប្រជុំរបស់ គ.ក.ជ. និងអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ នៃ គ.ក.ជ.
- កោះប្រជុំសាមញ្ញឬក្នុងករណីចាំបាច់ប្រជុំវិសាមញ្ញរបស់គ.ក.ជ. និងរបស់គណៈកម្មាធិការប្រតិបត្តិ នៃ គ.ក.ជ.
- ទទួលខុសត្រូវលើការងារផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**មាត្រា៦.-**

អនុប្រធាន គ.ក.ជ. បំពេញកិច្ចការ និងភារកិច្ច តាមការប្រគល់ជូនពីប្រធាន។

**មាត្រា៧.-**

សមាជិក គ.ក.ជ. មានតួនាទី និងភារកិច្ចដូចតទៅ ៖

- ចូលរួមប្រជុំសាមញ្ញ និងវិសាមញ្ញរបស់ គ.ក.ជ.
- លើកកម្មវិធីនយោបាយ វិធានការ របាយការណ៍ សំណើផ្សេងៗ មក គ.ក.ជ.
- ផ្តល់យោបល់លើកម្មវិធីនយោបាយ វិធានការ របាយការណ៍ សំណើផ្សេងៗ មក គ.ក.ជ. ។

**មាត្រា៨.-**

គ.ក.ជ. ត្រូវកោះប្រជុំសាមញ្ញ ៣ (បី) ខែម្តង។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា៩.-**

ក.ក.ជ. មានគណៈកម្មាធិការប្រតិបត្តិមួយសម្រាប់ដឹកនាំការងារប្រចាំថ្ងៃ។ គណៈកម្មាធិការប្រតិបត្តិនៃ ក.ក.ជ. មានសមាសភាពដូចតទៅ ÷

- ប្រធាន ក.ក.ជ. ប្រធាន
- អនុប្រធាន ក.ក.ជ. អនុប្រធាន
- អគ្គលេខាធិការ ក.ក.ជ. សមាជិក
- អគ្គលេខាធិការរង ក.ក.ជ. សមាជិក។

**មាត្រា១០.-**

គណៈកម្មាធិការប្រតិបត្តិនៃ ក.ក.ជ. ត្រូវប្រជុំយ៉ាងតិច១(មួយ) ខែម្តង ដើម្បីត្រួតពិនិត្យ និងបូកសរុបការងារ។

**មាត្រា១១.-**

ក.ក.ជ. មានសិទ្ធិអញ្ជើញប្រធាន ឬ តំណាងស្ថាប័ន ឬ ទីប្រឹក្សាតាមការចាំបាច់ ដើម្បីចូលរួមប្រជុំ ក.ក.ជ. ឬ ប្រជុំគណៈកម្មាធិការប្រតិបត្តិនៃ ក.ក.ជ.។

**មាត្រា១២.-**

គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ មានភារកិច្ចផ្តល់ឯកសារ ទិន្នន័យ និងព័ត៌មាន ជូន ក.ក.ជ. និងផ្តល់កិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ជាមួយក.ក.ជ.ដើម្បីបំពេញការងារប្រកបដោយប្រសិទ្ធភាពខ្ពស់ជូនរាជរដ្ឋាភិបាល។

**មាត្រា១៣.-**

ក.ក.ជ. ត្រូវមានតំណាងចូលរួមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី អន្តរក្រសួង និងកិច្ចប្រជុំផ្សេងៗទៀត តាមការអញ្ជើញរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា១៤.-**

ការប្រព្រឹត្តទៅនៃអង្គប្រជុំរបស់ ក.ក.ជ. និងគណៈកម្មាធិការប្រតិបត្តិនៃ ក.ក.ជ. ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ ក.ក.ជ.។

**មាត្រា១៥.-**

ក.ក.ជ. មានសិទ្ធិប្រើប្រាស់ត្រាដោយឡែករបស់ខ្លួន។

**មាត្រា១៦.-**

ក.ក.ជ. មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ដែលដឹកនាំដោយអគ្គលេខាធិការមួយរូប និងមានអគ្គលេខាធិការរងមួយចំនួនជាជំនួយការ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវតែងតាំងដោយ ព្រះរាជក្រឹត្យ ។

**មាត្រា១៧.-**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ ក.ក.ជ. ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី៥

## ប្រភពធនធាន

**មាត្រា១៨.-**

**ក.ក.ជ.** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី ។

**ក.ក.ជ.** មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិដែលបានមក ពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការបរទេស និងពីប្រភពផ្សេងទៀត សម្រាប់បំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា១៩.-**

ព្រះរាជក្រឹត្យនេះជំនួសព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/១០៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ដែលត្រូវបាននិរាករណ៍ ។

**មាត្រា២០.-**

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៩

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

៣រល.០៩០៩. ៩៩២

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្ថលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ : ៨១៦ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០០៩

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន ចាន់ថុល**